# ទង់ជ័យសម្រាប់អស់ទាំងសាសន៍

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*បើយើងបង្រៀនដោយព្រះវិញ្ញាណ ហើយអ្នកបានស្ដាប់ដោយព្រះវិញ្ញាណ នោះនឹងមានអ្នកនិយាយណាម្នាក់នឹងលើកឡើងនូវអ្វីមួយដែលទាក់ទងនឹងស្ថានភាពរបស់អ្នក ។*

មុនចាកចេញពីក្រុងណៅវូ នារដូវរងាក្នុងឆ្នាំ 1846 ប្រធាន ព្រិកហាំ យ៉ង់ បានសុបិនឃើញទេវតាមួយអង្គឈរនៅលើភ្នំមួយដែលមានរាងកោននៅទីកន្លែងមួយក្នុងទិសខាងលិច ដោយចង្អុលទៅជ្រលងភ្នំមួយនៅខាងក្រោម ។ពេលលោកបានទៅដល់ជ្រលងភ្នំ សលត៍ លេក ប្រមាណជា 18 ខែក្រោយមក នោះលោកបានឃើញពីទីតាំងដែលយើងបានជួបជុំគ្នានៅពេលនេះ ពីលើទីតាំងនេះបន្តិច គឺជាជាយភ្នំតែមួយដែលលោកបានឃើញនៅក្នុងការនិមិត្ត ។

ដូចដែលបានប្រាប់ជារឿយៗពីលើវេទិកានេះ បងប្រុស ព្រិកហាំ បាននាំអ្នកដឹកនាំមួយចំនួនទៅកាន់កំពូលភ្នំនោះ ហើយបានប្រកាសថា វាគឺជា« ទង់ជ័យនៅលើកំពូលភ្នំ » ជាឈ្មោះមួយដែលបានបំពេញអត្ថន័យខាងសាសនាសម្រាប់សាសន៍អ៊ីស្រាអែលសម័យទំនើបទាំងនេះ ។កាលពីពីរពាន់ប្រាំរយឆ្នាំមុនព្យាការី អេសាយ បានប្រកាសថា នៅថ្ងៃចុងក្រោយ « នោះភ្នំជាទីស្អាងព្រះវិហារនៃព្រះយេហូវ៉ានឹងបានតាំងឡើងខ្ពស់លើសអស់ទាំងភ្នំ ... ហើយ [ នៅទីនោះ ] ទ្រង់នឹងលើកទង់មួយឡើងសម្រាប់អស់ទាំងសាសន៍ » ។[1]

ដោយមើលឃើញថា សម័យកាលរបស់ខ្លួនសម្រេចការព្យាករណ៍នោះមិនបានពេញលេញ នោះបងប្អូនប្រុសចង់បង្ហូតនូវទង់ជ័យស្រដៀងគ្នានេះឡើងដើម្បីបង្កើតជាគំនិតនៃពាក្យថា « ទង់ជ័យសម្រាប់អស់ទាំងសាសន៍ » ។ អែលឌើរ ហ៊ីប៊ើរ ស៊ី គិមបុល បានហូតកន្សែងដៃពណ៌លឿងចេញមក ។ បងប្រុសព្រិកហាំយ៉ង់បានផ្សារភ្ជាប់ការណ៍នេះនឹងឈើជ្រាត់មួយដែលអែលឌើរ វិលហ្វដ វើឈើដស៍ បានកាន់ ហើយបានដាក់ទង់ជ័យច្នៃប្រឌិតនោះ ដោយប្រកាសថា ជ្រលងភ្នំនៃទីក្រុង សលត៍ លេក និងភ្នំដែលនៅជុំវិញនោះជាកន្លែងដែលបានព្យាករទុក ហើយជាកន្លែងដែលបន្ទូលនៃព្រះអម្ចាស់នឹងចេញទៅនាថ្ងៃចុងក្រោយ ។

បងប្អូនប្រុសស្រីទាំងឡាយ សន្និសីទទូទៅនេះ និងសន្និសីទពាក់កណ្ដាលឆ្នាំផ្សេងទៀត គឺជាការបន្តនៃការប្រកាសពីមុននោះដល់ពិភពលោក ។ ខ្ញុំថ្លែងទីបន្ទាល់ថា ព្រឹត្តិការណ៍ដែលបានកើតឡើងពីរថ្ងៃមកនេះគឺជាភស្តុតាងមួយទៀត ដូចដែលទំនុកតម្កើងបានចែងថា « មើលន៍ ទង់ជ័យនៃស៊ីយ៉ូនកំពុងបក់រិចៗ » ។[2] ហើយប្រាកដណាស់ថា ន័យពីរយ៉ាងនៃពាក្យ «បទដ្ឋាន » គឺមានជាអន្តរជាតិ ។ វាមិនមែនជារឿងចៃដន្យឡើយ ដែលការបោះពុម្ពជាភាសាអង់គ្លេសនៃសារលិខិតក្នុងសន្និសីទទូទៅរបស់យើងគឺស្ថិតក្នុងទស្សនាវដ្ដីមួយដែលមានឈ្មោះដ៏សាមញ្ញថា *The Ensign (*ទង់ជ័យ*)*នោះ ។

ខណៈដែលសន្និសីទរបស់យើងរៀបនឹងបញ្ចប់ ខ្ញុំសុំឲ្យអ្នកពិចារណានូវសារលិខិតដែលបានស្ដាប់ និងបាតុភូតដ៏ចម្លែកដែលសន្និសីទទូទៅនេះមាន ---ជាអ្វីដែលយើងជាពួកបរិសុទ្ធថ្ងៃចុងក្រោយជឿ សន្និសីទបែបនេះ និងអ្វីដែលយើងអញ្ជើញឲ្យពិភពលោកនេះស្ដាប់ ហើយសង្កេតមើលពីបញ្ហាទាំងនេះ ។យើងសូមថ្លែងទីបន្ទាល់ទៅគ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា ហើយនឹងគ្រប់ទាំងប្រជាជនថា សម្រាប់ជំនាន់យើងនិងនៅក្នុងសម័យយើង ពាក្យទូន្មានដែលអ្នកបានឮគឺស្ថិតនៅក្រោមការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ « ជាព្រះហឫទ័យនៃព្រះអម្ចាស់ ...ជាបន្ទូលនៃព្រះអម្ចាស់ ...ជាសម្លេងនៃព្រះអម្ចាស់ ហើយជាព្រះចេស្ដានៃព្រះចំពោះសេចក្ដីសង្គ្រោះ » ។[3]

ប្រហែលជាអ្នកបានដឹងរួចហើយ ( តែបើអ្នកមិនទាន់ដឹងនៅឡើយ នោះអ្នកគួរ ) ដឹងថា គ្មានបុរស ឬស្ត្រីណាម្នាក់ដែលបានឡើងនិយាយនៅទីនេះ កម្រនឹងត្រូវបានគេកំណត់ប្រធានបទឲ្យណាស់ ។ ពួកគាត់ម្នាក់ៗត្រូវតមអាហារហើយអធិស្ឋាន សិក្សាហើយស្វែងយល់ សរសេរម្ដងហើយម្ដងទៀត រហូតដល់គាត់ជឿថា សម្រាប់សន្និសីទនេះ នៅក្នុងខណៈនេះ ប្រធានបទរបស់គាតគឺជាប្រធានបទដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យពួកគាត់លើកឡើងនូវអ្វីដែលពួកគាត់ចង់លើកឡើង ។ បុរសស្ត្រីគ្រប់រូប អ្នករាល់គ្នាបានស្ដាប់ឮកាលពីដប់ម៉ោងកន្លងទៅក្នុងសន្និសីទទូទៅនេះបានព្យាយាមធ្វើតាមការបំផុសគំនិតនោះ ។

បុគ្គលម្នាក់ៗបានសម្រក់ទឹកភ្នែក មានការព្រួយបារម្ភ ហើយស្វែងរកដោយអស់ពីចិត្តនូវការណែនាំរបស់ព្រះអម្ចាស់ដើម្បីដឹកនាំគំនិត និងអារម្មណ៍ពួកគេ ។ដូចដែល ព្រិក ហាំយ៉ង់ បានឃើញទេវតាមួយអង្គឈរនៅលើទីនេះ នោះខ្ញុំក៏មើលឃើញពួកទេវតាទាំងនេះកំពុងឈរនៅក្នុងទីនេះដែរ ។ បងប្អូន

ប្រុសស្រីទាំងឡាយ ក្នុងចំណោមពួកអ្នកដឹកនាំទូទៅនៃសាសនាចក្រនឹងមិនសុខស្រួលក្នុងចិត្តចំពោះការហៅបែបនេះឡើយ តែនោះជារបៀបដែលខ្ញុំមើលឃើញពួកគាត់ ---គឺជាអ្នកនាំនូវសារលិខិតរបស់ទេវតា ជាបុរសស្ត្រីដែលជួបរាល់បញ្ហារូបកាយ បញ្ហាហិរញ្ញវត្ថុ និងបញ្ហាគ្រួសារដូចជាអ្នកនិងខ្ញុំដែរ តែជាមនុស្សដែលបានលះបង់ជីវិតរបស់ខ្លួនដោយក្តីជំនឿសម្រាប់ការហៅដែលពួកគេមាន និងចំពោះកាតព្វកិច្ចដើម្បីផ្សាយបន្ទូលនៃព្រះ ដែលមិនមែនពាក្យសម្តីរបស់គេ ។

ហើយសូមពិចារណាសារលិខិតផ្សេងៗគ្នាដែលបានស្តាប់ ដែលមានភាពអស្ចារ្យ ដោយគ្មានការសម្របសម្រួលនៃប្រធានបទណាមួយត្រូវបានធ្វើឡើង តែជាការដឹកនាំពីស្ថានសួគ៌ ។ ចុះហេតុអ្វីបានជាវាមិនដូចគ្នា ? ក្រុមជំនុំរបស់យើងភាគច្រើន ទាំងនៅទីនេះនិងកន្លែងផ្សេងទៀត ត្រូវបានបង្កើតជាសមាជិកសាសនាចក្រ ។ តែដោយវិធីសាស្ត្រនៃទូរគមនាគមន៍ថ្មីដ៏អស្ចារ្យជាច្រើន នោះអ្នកស្តាប់មួយផ្នែកធំសម្រាប់សន្និសីទយើងមិនមែនជាសមាជិកសាសនាចក្រ ។ ដូច្នេះ យើងត្រូវនិយាយទៅអ្នកដែលស្គាល់យើងយ៉ាងច្បាស់ និងអ្នកដែលមិនស្គាល់យើងសោះ ។សម្រាប់អ្នកដែលនៅក្នុងសាសនាចក្រ យើងត្រូវនិយាយទៅកាន់កុមារ យុវវ័យ ពួកមជ្ឈិមវ័យវ័យក្មេង មនុស្សវ័យកណ្តាល និងមនុស្សចំណាស់ ។ យើងត្រូវនិយាយទៅគ្រួសារ និងឪពុកម្តាយព្រមទាំងកុមារនៅតាមផ្ទះ ហើយយើងក៏និយាយទៅអ្នកដែលមិនទាន់រៀបការ អ្នកដែលគ្មានកូន និងប្រហែលជាអ្នកដែលនៅឆ្ងាយពីគ្រួសារផងដែរ ។

នៅក្នុងសន្និសីទទូទៅមួយ យើងតែងតែបញ្ជាក់ពីគោលការណ៍ដ៏អស់កល្បនៃក្តីជំនឿ ក្តីសង្ឃឹម ក្តីសប្បុរស[4] និងព្រះគ្រីស្ទដែលត្រូវបានគេឆ្កាង[5] ហើយក៏និយាយពីបញ្ហាសីលធម៌ដ៏ជាក់លាក់មួយចំនួននៅសម័យនេះផងដែរ ។ នៅក្នុងព្រះគម្ពីរ យើងបានបញ្ជាថា « ចូរកុំថាអ្វីដល់តំណនេះឡើយ លើកលែងតែការប្រែចិត្ត »[6] ខណៈពេលជាមួយគ្នាដែលយើងត្រូវផ្សាយ« ដំណឹងល្អដល់មនុស្សទាល់ក្រ [ និង ] ប្រោសមនុស្សដែលមានចិត្តសង្រេង » ។

ទោះជាស្ថិតក្នុងទម្រង់បែបណាក្តី សារលិខិតទាំងនេះក្នុងសន្និសីទ « ប្រកាសប្រាប់ពីឥស្សរភាពដល់ពួកជាប់ឃុំឃាំង » [7]ហើយប្រកាសប្រាប់ពី « សម្បត្តិរបស់ព្រះគ្រីស្ទដ៏ប្រមាណមិនបាន » ។[8] នៅក្នុងភាពខុសគ្នាទូទៅនៃការបង្រៀនដែលបានធ្វើឡើង គឺជាការសន្មតថា នឹងមានអ្វីមួយសម្រាប់មនុស្សគ្រប់គ្នា ។ ដោយគំនិតនេះ ខ្ញុំសន្និដ្ឋានថា ប្រធាន ហារ៉ូល ប៊ី លី បានពិពណ៌នាយ៉ាងល្អកាលពីប៉ុន្មានឆ្នាំមុន ពេលលោកបានមានប្រសាសន៍ថា « ពិតណាស់ ដំណឹងល្អគឺដើម្បីលួងលោមដល់ជនរងទុក្ខ ហើយធ្វើអ្នករងទុក្ខបានភាពសុខស្រួល » ។[9]

យើងតែងតែចង់ឲ្យការបង្រៀនយើងក្នុងសន្និសីទទូទៅប្រកបដោយក្តីសប្បុរស និងបើកចំហស្របតាមការបង្រៀនរបស់ព្រះគ្រីស្ទ ដោយចាំថាដូចជាយើងបង្រៀនពីវិន័យដែលតែងតែមានក្នុងសារលិខិតទ្រង់អញ្ចឹងដែរ ។ នៅក្នុងការបង្រៀនដ៏ល្អបំផុតដែលបានធ្វើឡើង ព្រះយេស៊ូវបានផ្តើមដោយប្រកាសពីពរជ័យដ៏អស្ចារ្យដែលយើងគ្រប់គ្នាចង់បាន ---ជាពរជ័យដែលបានសន្យាចំពោះអ្នកដែលកម្សត់ខាងឯវិញ្ញាណ អ្នកដែលមានចិត្តបរិសុទ្ធ អ្នកដែលផ្សះផ្សាគេ និងអ្នកដែលស្លូតត្រង់ ។[10] ការបង្រៀនទាំងនេះមាននូវការលើកតម្កើង និងការលួងលោមដល់ព្រលឹង ។ តែនៅក្នុងបង្រៀនដដែលនោះ ព្រះអង្គសង្គ្រោះបានបន្ត ដោយបង្ហាញពីរបៀបដែលអ្នកផ្សះផ្សាគេ និងអ្នកដែលមានចិត្តបរិសុទ្ធត្រូវធ្វើ ។

ទ្រង់បានមានបន្ទូលថា « អ្នករាល់គ្នាបានឮសេចក្តីដែលសំដែងដល់មនុស្សពីបុរាណថា « កុំឲ្យសម្លាប់មនុស្សឲ្យសោះ » ។ « តែខ្ញុំប្រាប់អ្នករាល់គ្នាដូច្នេះវិញថា សូម្បីតែអ្នកណាដែលខឹងបងប្អូន នោះក្រែងត្រូវជាប់ជំនុំជម្រះដែរ » ។[11] ហើយដូចគ្នានេះដែរ « អ្នករាល់គ្នាបានឮសេចក្តីដែលសម្តែងពីដើមថា កុំផិតឲ្យសោះ ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា សូម្បីតែអ្នកណាដែលគ្រាន់តែក្រឡេកឃើញស្ត្រី ហើយមានតម្រេកសម្រើបចង់បាន នោះឈ្មោះថាបានប្រព្រឹត្តសេចក្តីកំផិតនឹងនាងនោះក្នុងចិត្តខ្លួនហើយ»។[12]

ពិតណាស់ ពេលយើងក្លាយជាសិស្សដ៏ប្រពៃ នោះនឹងមានតម្រូវការជាច្រើនពីយើងរហូតដល់យើងអាចបំពេញតម្រូវការដ៏ធំនោះដែលបានប្រកាសក្នុងការបង្រៀននោះថា « ចូរអ្នករាល់គ្នាបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតានៃអ្នកដែលគង់នៅស្ថានសួគ៌ទ្រង់គ្រប់លក្ខណ៍ដែរ » ។[13] ការធ្វើជាសិស្សម្នាក់គឺមានភាពងាយស្រួលពេលយើងរៀនពីដំណឹងល្អជាលើកដំបូង តែវានឹងក្លាយជារឿងដ៏លំបាក ពេលយើងឈានទៅដល់កម្រិតដ៏ខ្ពស់បំផុតនៃភាពជាសិស្សដ៏ពិត ។ ពិតណាស់ អ្នកដែលគិតថា ព្រះយេស៊ូវបានបង្រៀនថាមនុស្សនឹងមិនទទួលខុសត្រូវចំពោះអំពើបាបខ្លួន គឺជាអ្នកដែលមិនបានអានព្រះគម្ពីរឲ្យបានល្អិតល្អន់ឡើយ ! មែនហើយ ក្នុងបញ្ហានៃភាពជាសិស្សរបស់យើង សាសនាចក្រមិនដូចជាភោជនីយដ្ឋានមួយដែលយើងអាចបញ្ជាទិញនូវអ្វីដែលយើងចង់បានឡើយ ។ នៅថ្ងៃណាមួយ *គ្រប់*ទាំងជង្គង់នឹងលុតចុះ ហើយ*គ្រប់*ទាំងអណ្តាតនឹងស្បថថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយថាការសង្គ្រោះអាចកើតមានតែតាមរបៀប*របស់ទ្រង់*ប៉ុណ្ណោះ ។[14]

ទោះជាយើងចង់ផ្សាយឲ្យត្រឹមត្រូវទាំងសេចក្តីពិតដ៏តឹងរ៉ឹង និងមានការលួងលោមនៃដំណឹងល្អក្នុងសន្និសីទទូទៅក្តី ក៏សូមចាំផងដែរថា ពេលយើងនិយាយពីប្រធានបទដែលពិបាកនឹងទទួលយក នោះយើងដឹងថា មនុស្សគ្រប់គ្នាពុំមែនកំពុងតែមើលរូបអាសគ្រាម ឬកំពុងជៀសវាងពីការរៀបការ ឬកំពុងមានទំនាក់ទំនងផ្លូវភេទមិនត្រឹមត្រូវទាំងអស់គ្នានោះទេ ។ យើងមិនបានដឹងថា មនុស្សគ្រប់គ្នាកំពុងតែល្មើសនឹងថ្ងៃឈប់សម្រាក ឬធ្វើទីបន្ទាល់ក្លែងក្លាយ ឬរំលោភបំពានលើភរិយានោះទេ ។ យើងដឹងថា អ្នកស្តាប់របស់យើងភាគច្រើន *ពុំមាន*ការព្រួយបារម្ភពីរឿងបែបនេះឡើយ តែយើងស្ថិតនៅក្រោមបញ្ញត្តិដ៏ពិសិដ្ឋមួយព្រមានដល់អ្នកដែលមានកំហុសចំពោះរឿងនេះ ទោះជានៅទីណាក្តីក្នុងពិភពលោកនេះ ។

ដូច្នេះ បើអ្នកកំពុងព្យាយាមធ្វើឲ្យអស់ពីលទ្ធភាពអ្នក ...ឧទាហរណ៍ បើអ្នកកំពុងព្យាយាមធ្វើរាត្រីជួបជុំក្រុមគ្រួសារ ទោះជាមានភាពរឹករវដែលពេលខ្លះកើតឡើងដោយសារមានក្មេងតូចៗ ---នោះសូមត្រង់ត្រាប់ស្តាប់នូវប្រធានបទដែលអ្នកធ្វើបានល្អ និងប្រធានបទមួយដែលត្រូវការការកែលំអឲ្យបានប្រសើរឡើង ។ បើយើងបង្រៀនដោយព្រះវិញ្ញាណ ហើយអ្នកបានស្តាប់ដោយព្រះវិញ្ញាណ នោះនឹងមានអ្នកនិយាយណាម្នាក់នឹងលើកឡើងនូវអ្វីមួយដែលទាក់ទងនឹងស្ថានភាពរបស់អ្នក ។

បងប្អូនប្រុសស្រីទាំងឡាយ ក្នុងសន្និសីទទូទៅ យើងរួមបញ្ចូលទីបន្ទាល់យើងនឹងទីបន្ទាល់ផ្សេងទៀតដែលនឹងកើតមាន ពីព្រោះទោះជាយ៉ាងណាក្តី ព្រះ*នឹង*ធ្វើឲ្យបន្ទូលរបស់ទ្រង់ត្រូវបានគេឮ ។

ព្រះអម្ចាស់បានមានបន្ទូលទៅពួកព្យាការីរបស់ទ្រង់ថា « យើងចាត់ឲ្យអ្នកទៅធ្វើបន្ទាល់ ហើយព្រមានប្រជាជន » ។[15]

« [ ហើយ ] បន្ទាប់ពីទីបន្ទាល់របស់អ្នក នោះទីបន្ទាល់អំពីផែនដីរំជួលនឹង ...អំពីសូរផ្គរលាន់ ...សូររន្ទះបាញ់ និង...ខ្យល់ព្យុះ និងសូររលកទឹកសមុទ្របោកហួសណាហួសណី ... ។

« ហើយពួកទេវតានឹង ...[ បន្លឺ ] សម្លេងយ៉ាងខ្លាំង ដោយបន្លឺត្រែនៃព្រះ » ។[16]

ពួកទេវតាទាំងនេះដែលឡើងមកកាន់វេទិកានេះ មាននូវរបៀបរៀងៗខ្លួន ដើម្បី« បន្លឺត្រែនៃព្រះ » ។ រាល់ការបង្រៀននីមួយៗមានទាំងទីបន្ទាល់និងការព្រមាន សូម្បីតែធម្មជាតិក្តី ក៏នឹងធ្វើទីបន្ទាល់ និងព្រមានក្នុងថ្ងៃចុងក្រោយនេះផងដែរ ។

បន្តិចទៀត ប្រធាន ម៉នសុន នឹងមកកាន់វេទិកាដើម្បីបញ្ចប់នូវសន្និសីទនេះ ។ ខ្ញុំប្រាប់រឿងមួយចំនួនពីបុរសម្នាក់នេះ ដែលជាសាវកច្បងនិងជាព្យាការីសម្រាប់សម័យដែលយើងកំពុងរស់នៅពេលនេះ ។ដោយពិចារណាពីទំនួលខុសត្រូវដែលខ្ញុំបានលើកឡើង នោះវាបង្ហាញឲ្យឃើញថាជីវិតរបស់ពួកព្យាការីគឺពុំងាយស្រួលឡើយ ហើយជីវិតប្រធាន ម៉នសុន ក៏ដូចគ្នាដែរ ។ លោកត្រូវបានហៅឲ្យធ្វើជាសាវកក្នុងវ័យ 36 ឆ្នាំ ហើយពេលនោះលោកមានកូនអាយុ 12 ឆ្នាំ 9 ឆ្នាំ និង4 ឆ្នាំ ។ បងស្រី ម៉នសុន ហើយនិងកូនៗ បានលះបង់ស្វាមី និងឪពុកខ្លួនសម្រាប់សាសនាចក្រ និងភារកិច្ចអស់រយៈពេលច្រើនជាងហាសិបឆ្នាំរហូតមកដល់ពេលនេះ ។ ពួកគេបានស៊ូទ្រាំនឹងជំងឺ និងតម្រូវការជាច្រើន ទាំងបញ្ហាតូចធំក្នុងជីវិតរមែងស្លាប់ដែលមនុស្សគ្រប់គ្នាជួប ដែលមានមួយចំនួនពួកគេនឹងជួបនៅពេលអនាគត ។ តែប្រធាន ម៉នសុន នៅតែរីករាយក្នុងគ្រប់ការណ៍ទាំងអស់ ។ គ្មានអ្វីមួយអាចធ្វើឲ្យលោកបាក់ទឹកចិត្តឡើយ ។ លោកមានក្តីជំនឿនិងកម្លាំងដ៏អស្ចារ្យ ។

ប្រធាន យើងស្រឡាញ់ហើយគោរពលោក ។ ការលះបង់របស់លោកគឺជាគំរូមួយសម្រាប់យើងគ្រប់គ្នា ។ យើងសូមអរគុណលោកចំពោះការដឹកនាំរបស់លោក ។ សម្រាប់អ្នកដប់បួននាក់ផ្សេងទៀតដែលកាន់តំណែងជាសាវក រួមទាំងអ្នកផ្សេងទៀតដែលអង្គុយលើវេទិកានេះ អ្នកដែលអង្គុយក្នុងក្រុមជំនុំនៅខាងមុខយើងផងដែរ ហើយមនុស្សដ៏ច្រើននៅជុំវិញពិភពលោកស្រឡាញ់អ្នក គាំទ្រអ្នក ហើយឈរប្រកៀកស្មាគ្នានឹងអ្នកក្នុងកិច្ចការនេះ ។ អ្នកជាអ្នកនាំសារម្នាក់របស់ទេវតា ដែលបានហៅតាំងពីមុនការបង្កបង្កើតពិភពលោកនេះទៅទៀត ដើម្បីគ្រវីទង់ជ័យនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទទៅពិភពលោកទាំងមូល ។

អ្នកកំពុងធ្វើការនេះបានយ៉ាងអស្ចារ្យ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ពីអ្វីដែលដំណឹងល្អប្រកាស និងពីការសង្គ្រោះដែលដំណឹងល្អបានផ្តល់ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. អេសាយ2:2; 11:12 ។

2. *Hymns* ទំព័រ 1 « The Morning Breaks » ។

3. គោលលទ្ធិ និងសេចក្ដីសញ្ញា 68:4។

4. សូមមើល កូរិនថូសទី 1 13:13 ។

5. សូមមើល កូរិនថូសទី 1 1:23 ។

6. គោលលទ្ធិ និងសេចក្ដីសញ្ញា 6:9; 11:9 ។

7. អេសាយ61:1 ។

8. អេភេសូរ 3:8 ។

9. សូមមើល Harold B. Lee ក្នុង « The Message » *New Era* ខែ មករា ឆ្នាំ 1971 ទំព័រ 6 ។

10. សូមមើល ម៉ាថាយ5:3–12 ។

11. ម៉ាថាយ5:21–22 សូមមើល នីហ្វៃទី 3 12:22 ។

12. ម៉ាថាយ 5:27–28 ។

13. ម៉ាថាយ 5:48 ។

14. សូមមើល រ៉ូម 14:11 ម៉ូសាយ 27:1 ។

15. គោលលទ្ធិ និងសេចក្ដីសញ្ញា 88:81 ។

16. គោលលទ្ធិ និងសេចក្ដីសញ្ញា 88:89–90, 92 ។